ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តព្រះសីហនុ
សំណុំរឿងព្រហ្មទណ្ឌលេខ៦៣ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១
សំណុំរឿងស៊ើបសួរលេខ៧៣ ម.ខ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០២១
សំណុំរឿងជំនុំជម្រះលេខ៤៦៨ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២២
កាលបរិច្ឆេទសវនាការថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២២
កាលបរិច្ឆេទប្រកាសសាលក្រមថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២២
សាលក្រមលេខ: ១១៣/០៧ ព្រ.៣ “ឈ”
ចុះថ្ងៃព្រហស្បតិ៍ ១០កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦
ត្រូវនឹងថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២២

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តព្រះសីហនុ

**<u>បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តព្រះសីហនុ</u>**

**<u>ដោយមានសមាសភាពដូចតទៅ</u>**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តព្រះសីហនុ

**ចៅក្រមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តព្រះសីហនុ

លោក [redacted] ចៅក្រមសាលាដំបូងសាលាខេត្តព្រះសីហនុ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តព្រះសីហនុ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តព្រះសីហនុ

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ៦៣ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តព្រះសីហនុ លើជនជាប់ចោទដូចខាងក្រោម ៖

១.ឈ្មោះ [redacted] KUN ហៅ A ZHU ភេទប្រុស អាយុ ២២ឆ្នាំ ជនជាតិចិន មុខរបរ បុគ្គលិកហាងម៉ាស្សា មានទីកន្លែងកំណើត ខេត្ត [redacted] ប្រទេសចិន កាន់លិខិតឆ្លងដែនលេខ [redacted] មានទីលំនៅមុនពេលឃុំខ្លួន ស្ថិតនៅភូមិ [redacted] ខេត្តព្រះសីហនុ នៅលីវ ឪពុក ឈ្មោះ [redacted] “រ” ម្ដាយឈ្មោះ [redacted] “រ” ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ **“គ្មាន”**។ **(ក្នុងឃុំ ៖ ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ៨៦ ត.៣/ជ/២១ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០២១)**

ជាប់ចោទពីបទ៖ **ឃាតកម្មគិតទុកជាមុន និងកាន់កាប់អាវុធដោយគ្មានការអនុញ្ញាត** ប្រព្រឹត្តនៅភូមិ១ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ បទល្មើសដែលបញ្ញត្តិផ្ដន្ទាទោសតាមមាត្រា **២០០** និងមាត្រា **៤៩០** នៃក្រមព្រហ្មទណ្ឌ។

២.ឈ្មោះ [redacted] XUAN YI ភេទប្រុស អាយុ ២៤ឆ្នាំ ជនជាតិចិន មុខរបរ អ្នកនាំភ្ញៀវចូល[illegible] មានទីកន្លែងកំណើត ខេត្ត [redacted] ប្រទេសចិន កាន់លិខិតឆ្លងដែនលេខ [redacted] មានទីលំនៅមុនពេលឃុំខ្លួនស្ថិតនៅ [redacted] ខេត្តព្រះសីហនុ នៅលើ ឪពុកឈ្មោះ [redacted] “រ” ម្ដាយឈ្មោះ [redacted] “រ” ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ **“គ្មាន”**។ **(ក្នុងឃុំ ៖ ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ[illegible] ត.៣/ជ/២១ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០២១)**



Scanned with CamScanner

51
10

៣.ឈ្មោះ [redacted] KAI JIN ភេទប្រុស អាយុ ២៣ឆ្នាំ ជនជាតិចិន មុខរបរ អ្នកនាំបុគ្គលិកធ្វើការអនឡាញ មានទីកន្លែងកំណើតនៅខេត្ត [redacted] ប្រទេសចិន កាន់លិខិតឆ្លងដែនលេខ [redacted] មានទីលំនៅមុនពេលឃុំខ្លួនស្ថិតនៅ [redacted] ខេត្តព្រះសីហនុ នៅលីវ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ "គ្មាន"។ **(ក្នុងឃុំ ៖ ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៨៨ គ.៣/ជ/២១ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០២១)**

ជាប់ចោទពីបទ៖ **សមគំនិតក្នុងអំពើឃាតកម្មគិតទុកជាមុន** ប្រព្រឹត្តនៅភូមិ១ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា២៩ និងមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ។

៤.ឈ្មោះ [redacted] FAN CONG ហៅ XIAO DONG ភេទប្រុស អាយុ ៣៤ឆ្នាំ ជនជាតិចិន មុខរបរ មិនពិតប្រាកដ មានទីកន្លែងកំណើតនៅខេត្ត [redacted] ប្រទេសចិន មានទីលំនៅមុនពេលឃុំខ្លួនស្ថិតនៅភូមិ [redacted] ខេត្តព្រះសីហនុ នៅលីវ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ "គ្មាន"។ **(ក្នុងឃុំ ៖ ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៤៩៩/២១ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ ២០២១)**

ជាប់ចោទពីបទ៖ **ឃាតកម្មគិតទុកជាមុន** ប្រព្រឹត្តនៅភូមិ១ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា **២០០** នៃក្រមព្រហ្មទណ្ឌ។

**មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទរួមមាន ៖**

១.លោក [redacted] **សុភា** អត្តលេខ [redacted] និងលោក [redacted] **វិសាល** អត្តលេខ [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] FAN CONG។

២.លោកស្រី [redacted] **គីមហួយ** អត្តលេខ [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] XUAN YI និងឈ្មោះ [redacted] KAI JIN។

៣.លោក [redacted] **ចិន្តា** និងលោក [redacted] **ដារ៉ា** ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] KAI JIN។

៤.លោក [redacted] **ចាន់ណុល** អត្តលេខ២១៧៧ ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] KUN។

**ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ** [redacted] **SHENG** ភេទប្រុស អាយុ ៣១ឆ្នាំ ជនជាតិចិន មានកន្លែងកំណើតនៅខេត្ត [redacted] ប្រទេសចិន មានទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តព្រះសីហនុ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] JIAN KUI "ស" ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ "គ្មាន"។

ដោយមានលោក [redacted] **លឹមដារា** អត្តលេខ [redacted] ជាអ្នកតំណាងដោយអាណត្តិឱ្យដើមបណ្តឹងរដ្ឋប្បវេណី។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ២៩១ អ.យ.ង/២១ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២២ របស់ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តព្រះសីហនុ។

បានឃើញ ដីកាដំណោះស្រាយលេខ១៥៥ ដ.ដ.ស (ជ)/២២ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះសីហនុ។

បានឃើញ ដីកាសម្រេចកំណត់កាលបរិច្ឆេទជំនុំជម្រះលេខ២៧៥៩ ត.ព.រ/២២ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តព្រះសីហនុ។

បានឃើញ ដីកាសម្រេចកំណត់កាលបរិច្ឆេទជំនុំជម្រះលេខ៣៨៦៤ ត.ព.រ/២២ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តព្រះសីហនុ។

**អង្គហេតុដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យមានដូចតទៅ**

កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ វេលាម៉ោង០៨ និង០០នាទីព្រឹក នៅចំណុចតាមបណ្តោយផ្លូវសណ្ឋាគារឯករាជ្យ (ឬសណ្ឋាគារប្រាំពីរជាន់) ស្ថិតនៅភូមិ១ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ជនសង្ស័យចំនួន ០៣នាក់ មានឈ្មោះ [redacted] KUN ភេទប្រុស, ឈ្មោះ [redacted] XUAN YI ភេទប្រុស និងឈ្មោះ WU KAI JIN ភេទប្រុស បានធ្វើសកម្មភាពដោយប្រើប្រាស់រថយន្តចំនួន ២គ្រឿង ម៉ាកFord Raptors ពណ៌ខ្មៅ ពាក់ស្លាកលេខ...



Scanned with CamScanner

56/9

ភ្នំពេញ ២BI-១៤១៣ និងម៉ាក Ford Ranger ពណ៌ស ពាក់ផ្លាកលេខ ភ្នំពេញ ២AF-៩៣៧៦ ធ្វើសកម្មភាពបើកដេញតាមរថយន្ត ០១គ្រឿង ម៉ាក Rang Rover ពណ៌ខ្មៅ ពាក់ផ្លាកលេខ ភ្នំពេញ ២AL-៩៤៥៩ ដែលជារថយន្តរបស់ជនរងគ្រោះឈ្មោះ [redacted] XU ភេទប្រុស។ លុះដល់ចំណុចកើតហេតុខាងលើ ជនល្មើសបានបើករថយន្តម៉ាក Ford Raptors ពណ៌ខ្មៅ ពាក់ផ្លាកលេខ ភ្នំពេញ ២BI-១៤១៣ ខាងលើទៅអែបនឹងរថយន្តរបស់ជនរងគ្រោះ រួចបានប្រើប្រាស់អាវុធខ្លីមួយដើម (មិនស្គាល់ម៉ាក) ធ្វើសកម្មភាពបាញ់ទៅលើជនរងគ្រោះ បណ្តាលឱ្យស្លាប់ភ្លាមៗនៅក្នុងរថយន្តនៅនឹងកន្លែងកើតហេតុតែម្តង។ គួរបញ្ជាក់ផងដែរថា នៅមុនពេលកើតហេតុ ជនរងគ្រោះបានជិះរថយន្ត១គ្រឿង ម៉ាក Rang Rover ពណ៌ខ្មៅ ពាក់ផ្លាកលេខ ភ្នំពេញ ២AL-៩៤៥៩ ជាមួយតៃកុងរថយន្ត (ជនជាតិខ្មែរ) ចេញពីកាស៊ីណូ ជីយ៉ូវនីសិន។ លុះដល់ចំណុចកើតហេតុខាងលើជនសង្ស័យបានបើករថយន្ត ០១គ្រឿង ម៉ាកFord Raptors ពណ៌ខ្មៅ ពាក់ផ្លាកលេខ ភ្នំពេញ ២BI-១៤១៣ ទៅអែបរថយន្តរបស់ជនរងគ្រោះ រួចបានធ្វើសកម្មភាពបាញ់ប្រហារទៅលើជនរងគ្រោះ ចំនួន ០២គ្រាប់ និងមានរថយន្តចំនួន ០៣គ្រឿងទៀត មានម៉ាក Ford-Ranger ពណ៌ស ពាក់ផ្លាកលេខ ២AF-៩៣៧៦, ម៉ាក Pruis ពណ៌ស មិនចាំផ្លាកលេខ និងម៉ាក ALPHARD ពណ៌ស គ្មានផ្លាកលេខ ជិះបិទគូថពីក្រោយ។ ភ្លាមនោះ តៃកុងរថយន្តជនជាតិខ្មែរ បានបើករថយន្តគេចត្រឡប់ទៅកាស៊ីណូ ជីយ៉ូវនីសិន វិញ ដើម្បីឱ្យគេជួយ ប៉ុន្តែជនល្មើសនៅតែបន្តបើករថយន្តប្រដេញតាមពីក្រោយដដែល ខណៈដល់ចំណុចមុខកាស៊ីណូ ជីយ៉ូវនីសិន តៃកុងរថយន្តជនជាតិខ្មែរបានឈប់រថយន្ត ហើយស្រែកឱ្យគេជួយ ភ្លាមៗនោះជនល្មើសក៏បានទៅដល់ហើយឈប់រថយន្តអែបនឹងរថយន្តរបស់ជនរងគ្រោះ រួចបាញ់សំដៅរថយន្តរបស់ជនរងគ្រោះបន្ថែមចំនួន២គ្រាប់ទៀត ទើបជនសង្ស័យបើករថយន្តគេចខ្លួន។ ដោយជនសង្ស័យមិនអាចបើករថយន្តគេចខ្លួនបាន ទើបជនសង្ស័យយករថយន្តទាំង២គ្រឿងនោះ ទៅប្លុងចោលនៅកន្លែងពីរផ្សេងគ្នា ដោយរថយន្តម៉ាក Ford Raptors ពណ៌ខ្មៅ ពាក់ផ្លាកលេខ ភ្នំពេញ ២BI-១៤១៣ ជនសង្ស័យយកទៅប្លុងចោលនៅលើដីឡូត៍ ០១កន្លែង ម្តុំរង្វង់មូលគោ២ ស្ថិតនៅភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ រីឯរថយន្តម៉ាក Ford Ranger ពណ៌ស ពាក់ផ្លាកលេខភ្នំពេញ ២AF-៩៣៧៦ យកទៅប្លុងចោលនៅចំណតរថយន្តក្រោយផ្សារទំនើបហ្វូវី ស្ថិតនៅភូមិ៣ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។ បន្ទាប់មកសមត្ថកិច្ចជំនាញធ្វើការទាក់ទងទៅម្ចាស់រថយន្តម៉ាក Ford Raptors ពណ៌ខ្មៅ ពាក់ផ្លាកលេខ ភ្នំពេញ២BI-១៤១៣ ដើម្បីស្វែងរកអត្តសញ្ញាណជនសង្ស័យ (លិខិតឆ្លងដែន) ទើបឈានដល់ការឃាត់ខ្លួនបានជនសង្ស័យឈ្មោះ [redacted] KAI JUN នៅចំណុចសណ្ឋាគារ កាង វ័ន្ត ស្ថិតនៅភូមិ២ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ដែលជាកន្លែងអ្នកជួលរថយន្តស្នាក់នៅហើយសមត្ថកិច្ចបន្តស្រាវជ្រាវ និងឆែកកាមេរ៉ាសុវត្ថិភាពតាមផ្លូវចាប់តាំងពីចំណុចដែលជនសង្ស័យយករថយន្តម៉ាក Ford Raptors ពណ៌ខ្មៅ ពាក់ផ្លាកលេខ ភ្នំពេញ ២BI-១៤១៣ ទៅប្លុងចោល ដោយនៅទីនោះមានជនសង្ស័យចំនួន៣នាក់ (សុទ្ធតែពាក់អាវខ្មៅ) បានចុះពីរថយន្តទើបសមត្ថកិច្ចជំនាញបន្តឆែកកាមេរ៉ាសុវត្ថិភាពតាមផ្លូវ រហូតដល់ចំណុចហាងបាយមុខសណ្ឋាគារ លីងហាង ហើយកម្លាំងសមត្ថកិច្ចក៏បានធ្វើរដ្ឋបាលឆែកឆេរនៅសណ្ឋាគា លីងហាង បន្ទប់លេខ ៨៥១២ ហើយធ្វើការឃាត់ខ្លួនបានជនសង្ស័យម្នាក់ទៀតឈ្មោះ [redacted] KUN ដោយឆែកឆេរក្នុងបន្ទប់លេខ ៨៥១២ រកឃើញមានប្រភេទសារធាតុញៀនដែលសង្ស័យជាសារធាតុញៀនរួមមាន ១.ម្សៅក្រាមពណ៌សថ្លាសង្ស័យជាសារធាតុញៀន ចំនួន ០១កញ្ចប់ ទម្ងន់សរុប ១៦,២៥ក្រាម, ២.ថ្នាំគ្រាប់អក្សរWY ចំនួន ០១កញ្ចប់ ទម្ងន់ ១៥,៨៨ក្រាម, ៣.ថ្នាំគ្រាប់ពណ៌ក្រហម ចំនួន ០១កញ្ចប់ ទម្ងន់ ២,៩៥ក្រាម, ៤.ថ្នាំគ្រាប់ពណ៌បៃតង ចំនួន ០១កញ្ចប់ ទម្ងន់សរុប ៦៣,៦៧ក្រាម, ៥.កញ្ឆាក្រៀម (រុក្ខជាតិញៀន) ចំនួន ០១កញ្ចប់ ទម្ងន់សរុប ៤,៥៤ក្រាម និងជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀន ចំនួន ០១គ្រឿង។ រួចសមត្ថកិច្ចបន្តធ្វើការឆែកកាមេរ៉ាសុវត្ថិភាព ឃើញថាមានជនសង្ស័យចំនួន ០២នាក់ទៀត បានចេញពីបន្ទប់លេខ៨៥១២ នៃសណ្ឋាគា លីងហាង ដើរទៅស្នាក់នៅសណ្ឋាគារដែលនៅក្បែរនោះ ទើបកម្លាំងសមត្ថកិច្ចបន្តធ្វើរដ្ឋបាលនៅសណ្ឋាគារ ០១ទៀត ដែលនៅកែងផ្លូវចំការស្តៅ ហើយបានធ្វើការឃាត់ខ្លួនបានជនសង្ស័យម្នាក់ទៀតឈ្មោះ [redacted] XUAN YI ចំណែកជនសង្ស័យម្នាក់ទៀត ព្រមទាំងបក្ខពួក កម្លាំងសមត្ថកិច្ចជំនាញកំពុងស្វែងរកឃាត់ខ្លួន។ ចំពោះរថយន្ត ០២គ្រឿង ១.ម៉ាក Ford Raptors ពណ៌ខ្មៅ ពាក់ផ្លាកលេខ ភ្នំពេញ ២BI-១៤១៣ (ជាមធ្យោបាយជិះប្រព្រឹត្តបទល្មើស និងមានសំបកកាទុស៤គ្រាប់ បន្សល់ទុកនៅលើកៅអីមុខ ផ្នែកខាងស្តាំក្នុងរថយន្តនេះ), ២.ម៉ាក Ford Ranger ពណ៌ស ពាក់ផ្លាកលេខ ភ្នំពេញ ២AF-៩៣៧៦ (ជាមធ្យោបាយជិះប្រព្រឹត្តបទល្មើស ជិះបិទគូថ) និងវត្ថុតាងផ្សេងៗទៀត ត្រូវបាន



Scanned with CamScanner

សមត្ថកិច្ចដកជាបណ្តោះអាសន្ន។ តាមការពិនិត្យកន្លែងកើតហេតុ លទ្ធផលកោសលវិច័យលើស្លាកស្នាមសាកសព និងរថយន្តទាំង ០២គ្រឿង ហើយជនសង្ស័យអង្គុយនៅកៅអីខាងចំហៀងខាងស្តាំ ជាកន្លែងដែលខ្សាំងកាំភ្លើងបាញ់ចេញ ថែមទាំងសំបកកាទុសបានធ្លាក់នៅកៅអី ដែលជនសង្ស័យអង្គុយទៀត ដែលនេះបង្ហាញឱ្យឃើញថា ជនសង្ស័យឈ្មោះ [redacted] KUN ជាអ្នកបាញ់សម្លាប់ជនរងគ្រោះពិតមែន ប៉ុន្តែជនសង្ស័យរឹងរូសមិនព្រមសារភាព ដោយម្តងឆ្លើយថា អ្នកបើករថយន្តជា អ្នកបាញ់ ហើយម្តងទៀតថា អ្នកដែលជិះពីក្រោយជាអ្នកបាញ់ទៅវិញ។ ក្រោយការសាកសួរឃើញថាមានពាក់ព័ន្ធនឹងជនសង្ស័យឈ្មោះ [redacted] GE, ឈ្មោះ [redacted] SHAO HONG ហៅ PANG ZI, ឈ្មោះ [redacted] LIAN QI និងឈ្មោះ [redacted] DONG ជាមេក្លោង និងជាអ្នករៀបចំផែនការបាញ់សម្លាប់ ចំណែកជនសង្ស័យឈ្មោះ [redacted] XUAN YI និងឈ្មោះ [redacted] KAI JIN ពិតជាបានសហការសមគំនិតគ្នាប្រព្រឹត្តករណីខាងលើនេះពិតមែន។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] KUN បានឆ្លើយថា៖ នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ ខ្លួនមិនបានចូលរួមសម្លាប់ជនរងគ្រោះនោះទេ ហើយនៅថ្ងៃសម្លាប់ជនរងគ្រោះខ្លួនក៏មិនបានជិះឡានជាមួយគេដែរ។ ខ្លួនមិនទទួលស្គាល់ចម្លើយដែលខ្លួនបានឆ្លើយកន្លងមកនោះទេ ព្រោះខ្លួនមិនបានប្រព្រឹត្ត ហើយខ្លួនក៏មិនបានដឹងថានរណាជាអ្នកប្រព្រឹត្តដែរ។ នៅថ្ងៃកើតហេតុខ្លួនបាននៅជាមួយឈ្មោះ [redacted] XUAN YI ដោយបាននៅជាមួយគេនៅមុនពេលកើតហេតុ ហើយនៅវេលាកើតហេតុក៏បាននៅជាមួយគ្នាដែរ តែនៅក្នុងបន្ទប់ស្នាក់នៅ។ ខ្លួនមិនស្គាល់ឈ្មោះ [redacted] FAN CONG នោះទេ។ ចំពោះអាវុធខ្លួនមិនបានដឹងទេ។ ខ្លួនស្គាល់ឈ្មោះ [redacted] XUAN YI និងឈ្មោះ [redacted] KAI JIN។ នៅថ្ងៃកើតហេតុខ្លួនបានដឹងហេតុការណ៍បាញ់គ្នាតាមរយៈឈ្មោះ ZHANG XUAN YI ជាអ្នកប្រាប់ខ្លួន។ ខ្លួនចាំចម្លើយតទល់ដែលខ្លួនបានឆ្លើយនៅតុលាការកាលពីខែកុម្ភៈ ឆ្នាំ២០២២ ដែលបានឆ្លើយថា "មានគេបង្គាប់ឱ្យខ្លួនឆ្លើយថា ឈ្មោះ [redacted] FAN CONG ជាអ្នកសម្លាប់គេ" ជាសង្សាររបស់ឈ្មោះ [redacted] XUAN YI ហើយគាត់មានឈ្មោះអ្វី ខ្លួនមិនស្គាល់ទេ ហើយគាត់ជាអ្នកបង្គាប់ឱ្យខ្លួនឆ្លើយបែបនេះ "ឈ្មោះ [redacted] FAN CONG ជាអ្នកសម្លាប់"។ ខ្លួនស្គាល់ឈ្មោះ [redacted] KAI JIN ហើយនៅពេលកើតហេតុគេបានចូលរួមជាមួយគេ ឬអត់? ខ្លួនមិនបានដឹងឡើយ។ នៅថ្ងៃកើតហេតុខ្លួនលេងបៀរ និងបានទៅណាឡើយ។

-ជនជាប់ចោទឈ្មោះ [redacted] XUAN YI បានឆ្លើយថា៖ នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ ខ្លួនមិនបានដឹងអំពីហេតុការណ៍បាញ់សម្លាប់នោះទេ ក្រោយមកឈ្មោះ HUANG KUN ប្រាប់ ទើបខ្លួនបានដឹង។ គាត់បានប្រាប់ថា ដូចឮសូរសម្លេងកាំភ្លើង ដោយមិនបានប្រាប់ថា គាត់សម្លាប់មនុស្សឡើយ។ ចំពោះរថយន្ត០១គ្រឿង ម៉ាក FORD RAPTOR មិនមែនជារបស់ខ្លួនជួលគេទេ ហើយខ្លួនមិនបានដឹងថា នរណាជាអ្នកជួលឡើយ។ ចំពោះជនជាប់ចោទទាំងអស់ ខ្លួនស្គាល់តែឈ្មោះ [redacted] KUN ម្នាក់ប៉ុណ្ណោះ។ ក្រោយពេលឈ្មោះ [redacted] KUN ប្រាប់បែបនេះ ខ្លួនមិនបានឱ្យគេជូនខ្លួនទៅណាឡើយ។ គេបានប្រាប់ខ្លួននៅកន្លែងស្នាក់នៅ វេលាម៉ោងមិនចាំ ដឹងតែនៅពេលព្រលឹម ថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ និងជាថ្ងៃដែលគេចាប់ខ្លួន។ ខ្លួនស្គាល់ឈ្មោះ [redacted] KUN ប្រហែលកន្លះឆ្នាំមកហើយ ដោយស្គាល់គ្នានៅខេត្តព្រះសីហនុ និងធ្លាប់ធ្វើការងារជាមួយគ្នា។ ខ្លួនមិនបានចូលរួមជាមួយគេនោះទេ។ ខ្លួនមិនបានដឹងថាមានហេតុការណ៍បាញ់សម្លាប់មនុស្សនោះទេ។ អំឡុងពេលកើតហេតុខ្លួនកំពុងស្នាក់នៅក្នុងបន្ទប់នៃសណ្ឋាគារ ហ៊ឺលិ បន្ទប់លេខ២០៧ ជាមួយស្រ្តីម្នាក់ជាសង្សាររបស់ខ្លួន ជនជាតិចិន ហើយនៅអំឡុងពេលនោះខ្លួនបាននៅជាមួយសង្សាររបស់ខ្លួនមិនបានទៅណាឡើយ។ សមត្ថកិច្ចបានមកឃាត់ខ្លួននៅក្នុងបន្ទប់ ហើយនៅក្នុងបន្ទប់នោះមានខ្នោះដៃចំនួន ០១ ដែលទុកសម្រាប់ប្រើពេលរួមភេទ។ នៅពេលទៀបភ្លឺ ខ្លួនបាននៅជាមួយសង្សាររបស់ខ្លួនរហូត ហើយខ្លួនបានរស់នៅជាមួយសង្សាប្រហែល ០២ខែមកហើយ។ អំឡុងពេលនោះខ្លួនមិនទាន់មានការងារធ្វើឡើយ។

-ជនជាប់ចោទឈ្មោះ [redacted] KAI JIN បានឆ្លើយថា៖ ខ្លួនមិនបានដឹងថានៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ មានហេតុការណ៍បាញ់សម្លាប់មនុស្សនោះទេ។ ក្នុងចំណោមអ្នកដែលសមត្ថកិច្ចឃាត់ខ្លួននោះ ខ្លួនស្គាល់តែឈ្មោះ [redacted] KUN ម្នាក់ប៉ុណ្ណោះ។ ចំពោះរថយន្ត ០១គ្រឿង ម៉ាក FORD RAPTOR គឺឈ្មោះ ចាង លានស៊ី ([redacted] LIAN QI) ជាអ្នកជួល មិនមែនខ្លួនជាអ្នកជួលនោះទេ ហើយគេជាអ្នកស្គាល់គ្នាជាមួយខ្លួន។ ឡាននោះខ្លួនមិនធ្លាប់បើកប្រើ ប៉ុន្តែខ្លួនធ្លាប់ជិះជាមួយគេ។ នៅយប់ថ្ងៃទី២០ ខែមករា ឆ្នាំ២០២១ ឈ្មោះ ចាង លានស៊ី ([redacted] LIAN QI) បានបើកឡាននោះឱ្យខ្លួនពី KTV មកបន្ទប់ស្នាក់នៅ ហើយខ្លួនបានស្នាក់នៅបន្ទប់រហូតមិនបានទៅណាឡើយ។ ខ្លួនមិនបានដឹងថា នរណាជាអ្នកបាញ់សម្លាប់ជនរងគ្រោះទេ ហើយឈ្មោះ [redacted] KUN ក៏មិនបានប្រាប់ខ្លួនដែរ។ ចំពោះចម្លើយដែលខ្លួនបានឆ្លើយនៅដំណាក់



Scanned with CamScanner

កាលសមត្ថកិច្ច ខ្លួនមិនទទួលស្គាល់នោះទេ ព្រោះគេបានវាយខ្លួន តែខ្លួនទទួលស្គាល់ចម្លើយនៅតុលាការ។ ខ្លួនស្គាល់ឈ្មោះ [redacted] KUN ហើយនៅថ្ងៃកើតហេតុខ្លួនមិនបានដឹងថាគេទៅកន្លែងណាទេ ដោយនៅថ្ងៃនោះខ្លួននៅក្នុងបន្ទប់ម្នាក់ឯង មិនមានអ្នកផ្សេងទៀតឡើយ។ ខ្លួនទទួលបានព័ត៌មានការបាញ់សម្លាប់នៅវេលាម៉ោង១០ ដោយមិត្តភក្តិរបស់ខ្លួនបានផ្ញើឱ្យមើល។ សមត្ថកិច្ចបានឃាត់ខ្លួននៅពេលខ្លួនចេញពីសណ្ឋាគារជាមួយស្ត្រីម្នាក់។ ខ្លួនមិនបានដឹងថា ហេតុអ្វីគេឃាត់ខ្លួននោះទេ ប្រហែលឈ្មោះ ចាង លានស៊ី ([redacted] LIAN QI) ជួលបន្ទប់នៅសណ្ឋាគារនោះដែរ ទើបគេមកឃាត់ខ្លួន។ ខ្លួនបានជិះឡានជាមួយឈ្មោះ ចាង លានស៊ី ([redacted] LIAN QI) មុនពេលកើតហេតុដោយគេបានជូនខ្លួនមកកន្លែងគេង។ ខ្លួនបានស្នាក់នៅបន្ទប់នោះតែម្នាក់ឯងទេ។ ចំពោះចម្លើយដែលខ្លួនបានឆ្លើយនៅតុលាការពីមុន ខ្លួនទទួលស្គាល់។

-ជនជាប់ចោទឈ្មោះ [redacted] FAN CONG បានឆ្លើយថា ៖ ខ្លួនទទួលស្គាល់ចម្លើយដែលខ្លួនបានឆ្លើយនៅតុលាការ។ មុនពេលកើតហេតុខ្លួនមិនបានចូលKTV ជីយ៉ូវនីសិន នោះទេ។ ខ្លួនបានទៅ KTV ០១កន្លែង នៅវេលាទាបភ្លឺ ប្រហែលថ្ងៃទី២០ ឬ២១ ខែមករា ឆ្នាំ២០២១ មិនបានប្រើប្រាស់គ្រឿងញៀនឡើយ ដោយពេលនោះខ្លួនទៅតែម្នាក់ឯង ជិះរថយន្ត ០១គ្រឿង ម៉ាក ALPHAD ពណ៌ស។ ខ្លួនស្នាក់នៅសណ្ឋាគារ ស៊ិនហុងលិ មិនមែននៅភ្នំពេញនោះទេ និងបានស្នាក់នៅក្នុងសណ្ឋាគារនេះប្រហែល កន្លះឆ្នាំមកហើយ។ ខ្លួនមិនស្គាល់អ្នកផ្សេងទៀតនោះទេ។ ខ្លួនមិនបានទៅសណ្ឋាគារជីយ៉ូនីស៊ិន នោះទេ តែខ្លួនបានទៅសណ្ឋាគារជីហារ បន្ទាប់មកខ្លួនទៅដំរី៥។ ចំពោះសាក្សីជាមនុស្សប្រុស ជនជាតិខ្មែរ ជាតៃកុងឡានរបស់ខ្លួន ហើយក៏ជាមិត្តភក្តិខ្លួន។ ចំណែកសាក្សីជាស្ត្រី ជនជាតិខ្មែរ គឺជាអ្នកបកប្រែ និងជាមិត្តភក្តិរបស់ខ្លួន ហើយគេមានការងារជាអ្នកបកប្រែ។ ម្នាក់ប្រុសឈ្មោះ **អាយ៉ុង** និងម្នាក់ស្រីឈ្មោះ **ស៊ាវលីន** ក្រៅពីការងារខាងលើ គេមិនមានការងារអ្វីផ្សេងទៀតទេ ដែលគេអាចបញ្ជាក់ថា ខ្លួនបានទៅដំរី៥ លេងហ្គេមបាញ់ត្រី នៅព្រឹកថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ ប្រហែលម៉ោង ០៦ និង ៣០នាទី ទៅម៉ោង០៧ព្រឹក រហូតដល់រសៀល ដោយនៅជាមួយគ្នារហូត។ តៃកុងឡានរបស់ខ្លួនបើកឡានដែលក្រុមហ៊ុនប្រើប្រាស់ម៉ាក TOYOTA ពណ៌ប្រផេះ មិនមែនជាឡានដឹកភ្ញៀវទេ ចំណែកម្នាក់ស្រីគេចេះចែកបៀរ តែនៅពេលនោះគេចាំបកប្រែឱ្យខ្លួន។ នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ ខ្លួនបានជិះ PASS APP មក មិនមែនឈ្មោះ **អាយ៉ុង** ជាអ្នកឌុបមកទេ។ ហើយខ្លួនបានជួបអាយ៉ុង នៅទីនោះ ដោយគេអង្គុយជិតខ្ញុំ (មានឈ្មោះ **លីន** និងឈ្មោះ **អាយ៉ុង**)។ នៅថ្ងៃនោះខ្ញុំលេងហ្គេមបាញ់ត្រីតែមួយមុខប៉ុណ្ណោះ។ នៅថ្ងៃកើតហេតុខ្លួននៅដំរី៥ ដោយមានឈ្មោះ **អាយ៉ុង** និងឈ្មោះ **អាលីន** បានដឹង។ ខ្លួននៅខេត្តព្រះសីហនុ មានក្រុមហ៊ុន សន្តិសុខ ឈ្មោះ **ជីងអ៊ីង៉**។ ចំពោះកាស៊ីណូដំរី៥ មានឈ្មោះ **តាស៊ីយ៉ាង**។ នៅពេលគេបាញ់នោះខ្លួននៅកាស៊ីណូ។ ខ្លួនមិនធ្លាប់ស្គាល់ និងមានទំនាក់ទំនងជាមួយអ្នកផ្សេងទៀតនោះទេ។ នៅពេលខ្លួនលេងកាស៊ីណូនោះឈ្មោះ **អាយ៉ុង** និងឈ្មោះ **អាលីន** នៅជាមួយរហូតដល់ខ្លួនចេញវិញ ហើយខ្លួនបានជិះឡាន ALPHAD ទៅភ្នំពេញ។

-សាក្សីឈ្មោះ [redacted] **យ៉ុង** បានឆ្លើយថា ៖ ខ្លួនស្គាល់ឈ្មោះ [redacted] DONG តាមរយៈគាត់លេងបៀរនៅក្នុងកាស៊ីណូ ឆាវឆឹង មិនមែននៅដំរី៥ នោះទេ។ ចំពោះឈ្មោះ [redacted] DONG គឺជាភ្ញៀវឧស្សាហ៍មកលេងនៅឆាវឆឹង ដែរ។ ខ្លួនមិនមានទំនាក់ទំនងអ្វីជាមួយឈ្មោះ [redacted] DONG នោះទេ ហើយនៅថ្ងៃកើតហេតុខ្លួនបានជូនភ្ញៀវទៅដំរី៥ ឃើញឈ្មោះ [redacted] **DONG** លេងហ្គេមបាញ់ត្រីនៅទីនោះ មិនបានជួបឈ្មោះ [redacted] DONG ទេ។ ខ្លួនមិនមានកាតនៅឆាវឆឹងទេ ប៉ុន្តែកន្លងមកខ្លួនធ្លាប់មាន។ បន្ទាប់ពីឃើញគេលេងហ្គេមរួច ខ្លួនបានទៅបត់ជើង (នោម) វេលាម៉ោង ០៧ព្រឹក ថ្ងៃទី២១ ខែមករា ឆ្នាំ២០២១។ ខ្លួនធ្លាប់បានចូលមកឆ្លើយករណីនេះចំនួន ០៣លើកមកហើយ។ ក្រោយមកខ្លួនបានដឹកភ្ញៀវទៅ និងបានត្រលប់មកវិញវេលាម៉ោងប្រហែល ០៩ ទៅម៉ោង ១០ព្រឹក។ ខ្លួនមិនមែនជាតៃកុងឡានរបស់ឈ្មោះ [redacted] DONG ទេ ប៉ុន្តែខ្លួនឧស្សាហ៍ឃើញគាត់ចែកលុយ នៅពេលគាត់លេងឈ្នះ។ ខ្លួនមិនធ្លាប់ស្គាល់ស្ត្រីដែលជាសាក្សីម្នាក់ទៀតនោះទេ ហើយក៏មិនបានឃើញអង្គុយជាមួយឈ្មោះ [redacted] DONG នៅថ្ងៃកើតហេតុនោះដែរ។ ខ្លួនមិនបានចូលលេងហ្គេម ឬអង្គុយនៅខាងក្នុងនោះទេ ហើយខ្ញុំមិនបានដឹងថាឈ្មោះ [redacted] DONG បានចេញពីកាស៊ីណូនៅពេលណា ខ្ញុំមិនដឹងទេ។

-សាក្សីឈ្មោះ [redacted] **លីន** បានឆ្លើយថា ៖ ខ្លួននៅកាស៊ីណូដំរី៥ ជាអ្នកចែកបៀរ និងឧស្សាហ៍ឃើញឈ្មោះ XIAO DONG នៅលេងហ្គេមនៅទីនោះ ដោយគេលេងហ្គេមបាញ់ត្រី តែមិនបានលេងតុខ្លួននោះទេ។ ខ្លួនមិនមែនជាអ្នកបកប្រែឱ្យឈ្មោះ [redacted] DONG នោះទេ។ ខ្លួនធ្វើការងារនៅកាស៊ីណូដំរី៥ ក្នុងឆ្នាំ២០២១ ធ្វើការងារបានរយៈពេល ០២ខែជាង (អំឡុងខែមេសា ដល់ខែឧសភា ឆ្នាំ២០២១)។ ខ្លួនធ្វើការងារវេនយប់ ពីម៉ោង ០៨យប់ ដល់ម៉ោង ០៨ព្រឹក ហើយពេលខ្លះក៏ប្តូរវេនផងដែរ។

-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ៖ ក្រោយបានស្តាប់ចម្លើយរបស់ជនជាប់ចោទ សាក្សី និងភស្តុតាង ឃើញថាជនជាប់ចោទបានឆ្លើយបដិសេធ ប៉ុន្តែតាមការស៊ើបអង្កេត និងរបាយការណ៍ឃើញថាមានភស្តុតាងគ្រប់គ្រាន់ និងមិនចម្លើយដែលចេញពីការបង្ខិតបង្ខំលើជនជាប់ចោទនោះទេ។ ជារួមគាត់មិនបានឆ្លើយសារភាពជាសិទ្ធិរបស់ពួកគាត់ តែចម្លើយមិនមានភស្តុតាង និងសាក្សីបញ្ជាក់ឱ្យបានច្បាស់ឡើយ។ ផ្ទុយមកវិញសាក្សី ០២រូប ដែលឆ្លើយនាពេលនេះគឺជាការផ្តល់នូវសេចក្តីកម្សត្តែង ដែលបញ្ជាក់ថា ជនជាប់ចោទមិនបានស្ថិតនៅកន្លែងកើតហេតុ។ ជារួមតំណាងអយ្យការស្នើសុំតម្កល់បទចោទតាមដីកាសន្និដ្ឋានស្ថាពរទុកជាត្រឹមត្រូវដដែល។

-សេចក្តីសន្និដ្ឋានរបស់លោកមេធាវី [redacted] ចាន់ណុល ៖ ក្រោយបានសាកសួរដេញដោលនាពេលសវនាការ កូនក្តីខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ឡើយ ហើយកូនក្តីខ្លួនបានបញ្ជាក់រួចហើយថា នៅថ្ងៃកូនក្តីខ្លួននៅបន្ទប់ស្នាក់នៅ។ ចំពោះចម្លើយកូនក្តីខ្លួនបានឆ្លើយនៅដំណាក់កាលសមត្ថកិច្ច គឺជាការបង្គាប់ឱ្យឆ្លើយតាមគេបង្គាប់បញ្ជាតែប៉ុណ្ណោះ។ ហេតុដូច្នេះ ក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] KUN ស្នើសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេចឱ្យជនត្រូវចោទរួចផុតបទចោទ។

-សេចក្តីសន្និដ្ឋានរបស់លោកស្រីមេធាវី [redacted] គឹមហួយ ៖ កូនក្តីខ្លួនឈ្មោះ [redacted] XUAN YI បានបញ្ជាក់ថា គាត់មិនបានប្រព្រឹត្តដូចការចោទប្រកាន់ឡើយ ហើយនៅថ្ងៃកើតហេតុគាត់បាននៅជាមួយសង្សាររបស់គាត់មិនបានទៅណាឡើយ។ ហេតុដូច្នេះស្នើសុំតុលាការសម្រេចឱ្យកូនក្តីខ្លួនឈ្មោះ [redacted] XUAN YI រួចផុតបទចោទប្រកាន់ ហើយការចោទប្រកាន់កូនក្តីខ្លួនដែលមិនបានប្រព្រឹត្តគឺអយុត្តិធម៌ ហើយបទល្មើសដែលចោទប្រកាន់ជាបទឧក្រិដ្ឋថែមទៀត។ ហេតុនេះខ្លួនស្នើសុំតុលាការពិនិត្យកាមេរ៉ាសុវត្ថិភាព និងទំនាក់ទំនងតាមទូរស័ព្ទរបស់កូនក្តីខ្លួន។ ដោយឡែកកូនក្តីខ្លួនឈ្មោះ [redacted] KAI JIN បានបញ្ជាក់ថា គាត់នៅតែក្នុងបន្ទប់ជាមួយមិត្តស្រី ដោយគាត់មិនបានប្រព្រឹត្តទេ បើគាត់បានប្រព្រឹត្តមែន មិនមែនគាត់មិនរត់នោះទេ ហើយការចាប់ខ្លួនកូនក្តីខ្លួននោះ គឺតាមរយៈរថយន្តប៉ុណ្ណោះ។ ហេតុដូច្នេះស្នើសុំតុលាការសម្រេចឱ្យកូនក្តីខ្លួនទាំង ០២នាក់រួចផុតបទចោទប្រកាន់។

-សេចក្តីសន្និដ្ឋានរបស់លោកមេធាវី [redacted] វិសាល ៖ កូនក្តីខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់របស់តំណាងអយ្យការឡើយ ព្រោះនៅថ្ងៃកើតហេតុគាត់នៅក្នុងកាស៊ីណូ។ ជាក់ស្តែងអ្វីដែលបានកើតឡើងជាការរៀបចំរបស់សង្សាររបស់ឈ្មោះ [redacted] LIAN YI ដែលបង្គាប់ឱ្យឈ្មោះ [redacted] KUN ឆ្លើយថាកូនក្តីខ្លួនឈ្មោះ [redacted] FAN CONG ជាអ្នកសម្លាប់ជនរងគ្រោះ និងជាអ្នករៀបចំ។ ហេតុនេះមិនមានភស្តុតាងបញ្ជាក់ថា កូនក្តីខ្លួនជាអ្នកបាញ់សម្លាប់ជនរងគ្រោះឡើយ។ ដូច្នេះក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] FAN CONG ស្នើសុំក្រុមប្រឹក្សាពិនិត្យ និងសម្រេចឱ្យកូនក្តីខ្លួនរួចផុតបទចោទ។

-សេចក្តីសន្និដ្ឋានរបស់លោកមេធាវី [redacted] សុភា ៖ ខ្លួនឯកភាពតាមការសន្និដ្ឋានរបស់សហភាតាលោកមេធាវី [redacted] វិសាល ខាងលើ។

-សេចក្តីសន្និដ្ឋានរបស់លោកមេធាវី [redacted] ដារ៉ា ៖ ក្រោយពីបានស្តាប់ការសាកសួរដេញដោលរួចមកឃើញថា ឈ្មោះ [redacted] KAI JIN បានដឹងហេតុការណ៍តាមរយៈឈ្មោះ [redacted] KUN ជាអ្នកប្រាប់។ ហើយមិនមានភស្តុតាងបញ្ជាក់ថា កូនក្តីខ្លួនបានប្រព្រឹត្តនោះទេ ហើយកូនក្តីខ្លួនបានស្គាល់ឈ្មោះ [redacted] KUN មុនពេលកើតហេតុនៃបទល្មើស ក្រោយពេលឃាត់ខ្លួនទើបឈានដល់ការឃាត់ខ្លួនកូនក្តីខ្លួន។ ម្យ៉ាងវិញទៀតនៅថ្ងៃកើតហេតុ កូនក្តីខ្លួនបានចូលបន្ទប់ស្នាក់នៅតាំងពីម៉ោង ០២ ទៅម៉ោង ០៣យប់ និងបានស្នាក់នៅក្នុងបន្ទប់តែម្នាក់ឯង ដោយបានដឹងការបាញ់សម្លាប់តាមរយៈឈ្មោះ [redacted] KAI JIN ក្រោយមកក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួន។ ចំពោះឡាន ALPHAD ពណ៌ស ជារបស់ឈ្មោះ [redacted] DONG តែរថយន្ត FORD RAPTOR ជារបស់ឈ្មោះ ចាង លានស៊ី ([redacted] LIAN QI) ដែលនេះបញ្ជាក់ថា កូនក្តីខ្លួនមិនមែនជាអ្នកជួលរថយន្តនោះទេ។ កូនក្តីខ្លួនមិនជាប់ពាក់ព័ន្ធនឹងបទល្មើស និងមានភស្តុតាងប្រព្រឹត្តបទល្មើសទេ។ មុនពេលកើតហេតុកូនក្តីខ្លួនបានទៅKTV ហើយជនជាប់ចោទផ្សេងទៀតក៏បានបញ្ជាក់ថា ពួកគេមិនស្គាល់កូនក្តីខ្លួនឈ្មោះ [redacted] KAI JIN ទេ។ ហេតុនេះស្នើសុំដល់ក្រុមប្រឹក្សាជំនុំជម្រះសម្រេចឱ្យរួចផុតបទចោទ។

-សំណូមពររបស់ជនជាប់ចោទឈ្មោះ [redacted] KUN ៖ គ្មាន។

-សំណូមពររបស់ជនជាប់ចោទឈ្មោះ [redacted] XUAN YI ៖ ស្នើសុំរួចផុតបទចោទ។

-សំណូមពររបស់ជនជាប់ចោទឈ្មោះ [redacted] KAI JIN ៖ ស្នើសុំរួចផុតបទចោទ។

-សំណូមពររបស់ជនជាប់ចោទឈ្មោះ [redacted] FAN CONG ៖ ស្នើសុំរួចផុតបទចោទ។



Scanned with CamScanner

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ
ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សី
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានកត់សំគាល់របស់តំណាងអយ្យការប្តឹងសុំ
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ
ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាដំបូងខេត្តព្រះសីហនុ
## យល់ឃើញថា

**១.**ជនជាប់ចោទឈ្មោះ [redacted] KUN បានឆ្លើយថា ៖ នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ ខ្លួនមិនបានចូលរួមសម្លាប់ជនរងគ្រោះនោះទេ និងមិនបានជិះឡានជាមួយគេដែរ។ ខ្លួនមិនទទួលស្គាល់ចម្លើយដែលខ្លួនបានឆ្លើយកន្លងមកទេ ព្រោះខ្លួនមិនបានប្រព្រឹត្ត។ នៅមុនពេលកើតហេតុខ្លួនបាននៅជាមួយឈ្មោះ [redacted] XUAN YI ហើយនៅវេលាកើតហេតុខ្លួននៅក្នុងបន្ទប់ស្នាក់នៅ។ ខ្លួនមិនស្គាល់ឈ្មោះ [redacted] FAN CONG នោះទេ។ ចំពោះអាវុធខ្លួនមិនបានដឹងទេ។ នៅថ្ងៃកើតហេតុខ្លួនបានដឹងហេតុការណ៍បាញ់គ្នាតាមរយៈឈ្មោះ [redacted] XUAN YI ជាអ្នកប្រាប់ខ្លួន។ ចម្លើយដែលខ្លួនបានឆ្លើយថា "មានគេបង្គាប់ឱ្យខ្លួនឆ្លើយថា ឈ្មោះ [redacted] FAN CONG ជាអ្នកសម្លាប់គេ" ជាសង្សាររបស់ឈ្មោះ [redacted] XUAN YI ហើយគាត់មានឈ្មោះអ្វី ខ្លួនមិនស្គាល់ទេ ហើយគាត់ជាអ្នកបង្គាប់ឱ្យខ្លួនឆ្លើយបែបនេះ "ឈ្មោះ [redacted] FAN CONG ជាអ្នកសម្លាប់"។ ដែលចម្លើយរបស់ជនជាប់ចោទខាងលើគ្រាន់តែជាការឆ្លើយដោះសារដើម្បីគេចវេសពីការទទួលខុសត្រូវព្រហ្មទណ្ឌ ដោយមិនមានភស្តុតាង និងសាក្សីមកបញ្ជាក់ឱ្យតុលាការជឿជាក់បានឡើយ ហើយក៏មិនមានជនជាប់ចោទណាជាសង្សាររបស់ឈ្មោះ ZHANG XUAN YI មកអះអាងដូចការលើកឡើងរបស់ឈ្មោះ [redacted] KUN ឡើយ ផ្ទុយមកវិញតាមចម្លើយរបស់ជនត្រូវចោទបានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរបានឆ្លើយថា នៅថ្ងៃកើតហេតុឈ្មោះ [redacted] DONG បានឡើងបើករថយន្ត និងបានឱ្យខ្លួនក្រាបក្បាលចុះក្រោម ក្រោយមកគេបានដកកាំភ្លើងបាញ់ចំនួន ០៣គ្រាប់ ហើយខ្លួនបានឮសម្លេងឆ្លើយឆ្លងជាមួយឈ្មោះ [redacted] GE ដោយគេបានឱ្យឈ្មោះ [redacted] DONG បើកឡានបុកជនរងគ្រោះ បែរជាគេបាញ់សម្លាប់ជនរងគ្រោះទៅវិញ ដែលចម្លើយជនជាប់ចោទត្រង់ចំណុចនេះ ស្របទៅនឹងចម្លើយដែលជនជាប់ចោទរូបនេះបានឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ដែលបានបញ្ជាក់ថា គម្រោងនៃការបាញ់សម្លាប់ជនរងគ្រោះ គឺឈ្មោះ [redacted] LIAN QI, ឈ្មោះ [redacted] ZI និងបក្សពួកផ្សេងទៀត ដែលបានជិះនៅក្នុងរថយន្តម៉ាកព្រុស, រថយន្តម៉ាក ALPHAD ពណ៌ស និងម៉ាក FORD RANGER ពណ៌ស មានស្លាកលេខ ភ្នំពេញ 2AF-9376 ជាអ្នករៀបចំទាំងអស់ ដែលមានអ្នកបញ្ជាពីក្រោយខ្នងគឺឈ្មោះ [redacted] GE។

**២.**ជនជាប់ចោទឈ្មោះ [redacted] **XUAN YI** បានឆ្លើយថា៖ នៅថ្ងៃកើតហេតុខ្លួនមិនបានដឹងអំពីហេតុការណ៍បាញ់សម្លាប់ទេ ក្រោយមកឈ្មោះ [redacted] KUN ប្រាប់ ទើបខ្លួនបានដឹង។ ចំពោះរថយន្ត០១គ្រឿង ម៉ាក FORD RAPTOR មិនមែនជារបស់ខ្លួនជួលគេទេ ហើយខ្លួនមិនបានដឹងថា នរណាជាអ្នកជួលឡើយ។ ចំពោះជនជាប់ចោទទាំងអស់ ខ្លួនស្គាល់តែឈ្មោះ [redacted] KUN ម្នាក់ប៉ុណ្ណោះ ប្រហែលកន្លះឆ្នាំមកហើយ និងធ្លាប់ធ្វើការងារជាមួយគ្នា។ អំឡុងពេលកើតហេតុខ្លួនកំពុងស្នាក់នៅក្នុងបន្ទប់នៃសណ្ឋាគារ ហ៊ីលិ បន្ទប់លេខ២០៧ ជាមួយស្ត្រីម្នាក់ជាសង្សាររបស់ខ្លួន ជនជាតិចិន មិនបានទៅណាឡើយ។ សមត្ថកិច្ចបានមកឃាត់ខ្លួននៅក្នុងបន្ទប់ ហើយនៅក្នុងបន្ទប់នោះមានខ្មោះដៃចំនួន ០១ ដែលទុកសម្រាប់ប្រើពេលរួមភេទ។ និងឈ្មោះ [redacted] KAI JIN បានឆ្លើយថា ៖ ខ្លួនមិនបានដឹងហេតុការណ៍បាញ់សម្លាប់មនុស្សនោះទេ។ ក្នុងចំណោមអ្នកដែលសមត្ថកិច្ចឃាត់ខ្លួននោះ ខ្លួនស្គាល់តែឈ្មោះ [redacted] KUN ម្នាក់ប៉ុណ្ណោះ។ ចំពោះរថយន្ត ០១គ្រឿង ម៉ាក FORD RAPTOR គឺឈ្មោះ ចាង លានស៊ី ([redacted] LIAN QI) ជាអ្នកជួល មិនមែនខ្លួនជាអ្នកជួលឡានទេ ហើយគេជាអ្នកស្គាល់គ្នាជាមួយខ្លួន។ នៅយប់ថ្ងៃទី២០ ខែមករា ឆ្នាំ២០២១ ឈ្មោះ ចាង លានស៊ី ([redacted] LIAN QI) បានទៅឱបខ្លួនពី KTV មកបន្ទប់ស្នាក់នៅ ហើយខ្លួនបានស្នាក់នៅបន្ទប់រហូតមិនបានទៅណាឡើយ។ ខ្លួនមិនបានដឹងថា នរណាជាអ្នកបាញ់សម្លាប់ជនរងគ្រោះទេ ហើយឈ្មោះ [redacted] KUN ក៏មិនបានប្រាប់ខ្លួនដែរ។ ខ្លួនទទួលបានព័ត៌មានការបាញ់សម្លាប់នៅវេលាម៉ោង១០ ដោយមិត្តភក្តិរបស់ខ្លួនបានផ្ញើឱ្យមើល។ សមត្ថកិច្ចបានឃាត់ខ្លួននៅពេលខ្លួនចេញពីសណ្ឋាគារ

ជាមួយស្ត្រីម្នាក់។ ខ្លួនមិនបានដឹងថា ហេតុអ្វីគេឃាត់ខ្លួននោះទេ ប្រហែលឈ្មោះ ចាង លានស៊ី ([redacted] LIAN QI) ជួលបន្ទប់នៅសណ្ឋាគារនោះដែរ ទើបគេមកឃាត់ខ្លួន។ ដែលចម្លើយរបស់ជនជាប់ចោទខាងលើពុំអាចឱ្យតុលាការជឿជាក់បានឡើយ ព្រោះជនជាប់ចោទទាំងអស់សុទ្ធជាបក្សពួកតែមួយដែលបានស្គាល់គ្នា និងបានចូលរួមធ្វើសកម្មភាពជាមួយគ្នាក្នុងការសម្លាប់ជនរងគ្រោះ និងបានស្ថិតនៅក្នុងហេតុការណ៍នៃការសម្លាប់នោះ ហើយបើតាមរបាយការណ៍លេខ ០៣៥ រ.ប.ក/២១ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ របស់ការិយាល័យព្រហ្មទណ្ឌកម្រិតស្រាល នៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ បានបញ្ជាក់ថា ការឃាត់ខ្លួនជនសង្ស័យឈ្មោះ [redacted]XUAN YI គឺតាមរយៈការឆែកកាម៉េរ៉ាសុវត្ថិភាពចាប់ពីចំណុចជនសង្ស័យយករថយន្តទៅប្តូងចោល រហូតត្រលប់មកសណ្ឋាគារដើម្បីស្នាក់នៅវិញ (កាម៉េរ៉ាសណ្ឋាគារ)។ ហើយតាមរបាយការណ៍មន្ត្រីនគរបាលយុត្តិធម៌ក៏បានបញ្ជាក់ដែរថា ជនជាប់ចោទឈ្មោះ [redacted] XUAN YI និងឈ្មោះ WU KAI JIN គឺជាអ្នកសមគំនិត ក្នុងករណីឃាតកម្មគិតទុកជាមុន កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ នៅចំណុចសណ្ឋាគារឯករាជ្យ ស្ថិតនៅភូមិ១ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ប្រាកដមែន។

**៣.ជនជាប់ចោទឈ្មោះ [redacted] FAN CONG ហៅ XIAO DONG** បានឆ្លើយថា ៖ ខ្លួនបានទៅ KTV ០១កន្លែងនៅវេលាទាបភ្លឺប្រហែលថ្ងៃទី២០ ឬ២១ ខែមករា ឆ្នាំ២០២១ មិនបានប្រើប្រាស់គ្រឿងញៀនឡើយ ដោយពេលនោះខ្លួនទៅតែម្នាក់ឯង ជិះរថយន្ត ០១គ្រឿង ម៉ាក ALPHAD ពណ៌ស។ ខ្លួនមិនបានទៅសណ្ឋាគារ ជីយ៉ូនីស៊ិន នោះទេ តែខ្លួនបាន ទៅសណ្ឋាគារជីហាវ បន្ទាប់មកខ្លួនទៅដំរី៥។ ចំពោះសាក្សីជាមនុស្សប្រុស ជនជាតិខ្មែរ ជាតៃកុងឡានរបស់ខ្លួន ហើយក៏ជាមិត្តភក្តិខ្លួន។ ចំណែកសាក្សីជាស្ត្រី ជនជាតិខ្មែរ គឺជាអ្នកបកប្រែ និងជាមិត្តភក្តិរបស់ខ្លួន ហើយគេមានការងារជា អ្នកបកប្រែ។ ម្នាក់ប្រុសឈ្មោះ **អាយ៉ុង** និងម្នាក់ស្រីឈ្មោះ **ស៊ាវលីន** ក្រៅពីការងារខាងលើ គេមិនមានការងារអ្វីផ្សេងទៀតទេ ដែលគេអាចបញ្ជាក់ថា ខ្លួនបានទៅដំរី៥ លេងហ្គេមបាញ់ត្រី នៅព្រឹកថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ ប្រហែលម៉ោង ០៦ និង ៣០នាទី ទៅម៉ោង០៧ព្រឹក រហូតដល់រសៀល ដោយនៅជាមួយគ្នារហូត។ នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ ខ្លួនបានជិះ PASS APP មក មិនមែនឈ្មោះ **អាយ៉ុង** ជាអ្នកឌុបមកទេ។ ខ្លួនបានជួបអាយ៉ុង នៅទីនោះ ដោយគេអង្គុយជិតខ្ញុំ (មានឈ្មោះ **លីន** និងឈ្មោះ **អាយ៉ុង**)។ ចំពោះកាស៊ីណូដំរី៥ មានឈ្មោះ **តាស៊ីយ៉ាង**។ នៅពេលគេបាញ់នោះខ្លួននៅកាស៊ីណូ។ ដែលចម្លើយរបស់ជនជាប់ចោទខាងលើមិនអាចឱ្យតុលាការជឿជាក់បានឡើយ ព្រោះតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted]KUN បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរថា នៅថ្ងៃកើតហេតុឈ្មោះ [redacted]DONG បានឡើងបើករថយន្ត និងបានឱ្យខ្លួនក្រាបក្បាលចុះក្រោម ក្រោយមកគេបានដកកាំភ្លើងបាញ់ចំនួន ០៣គ្រាប់ ហើយខ្លួនបានឮសម្លេងឆ្លើយឆ្លងជាមួយឈ្មោះ [redacted] GE ដោយគេបានឱ្យឈ្មោះ [redacted] DONG បើកឡានបុកជនរងគ្រោះ បែរជាគេបាញ់សម្លាប់ជនរងគ្រោះទៅវិញ។

**៤.តាមចម្លើយសាក្សីឈ្មោះ [redacted]យ៉ុង** និងឈ្មោះ **[redacted]លីន** បានឆ្លើយប្រហាក់ប្រហែលគ្នាថា ៖ នៅថ្ងៃកើតហេតុថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ វេលាម៉ោង ០៧ ទៅម៉ោង ០៨ព្រឹក ពួកខ្លួនបានឃើញឈ្មោះ [redacted] FAN CONG ហៅ XIAO DONG នៅក្នុងកាស៊ីណូ៥ មិនបានចេញទៅណានោះទេ។ សាក្សីទាំង ០២រូបក៏បានឆ្លើយបញ្ជាក់នៅដំណាក់កាលចៅក្រមស៊ើបសួរថា ឈ្មោះ [redacted] FAN CONG នៅលេងក្នុងកាស៊ីណូ នៅថ្ងៃកើតហេតុវេលាប្រហែលម៉ោង ០១រសៀល ទើបគេចេញពីកាស៊ីណូវិញ។ ដែលចម្លើយសាក្សីខាងលើតុលាការមិនអាចជឿជាក់បាននោះទេ ព្រោះការអះអាងនោះមិនមានមូលដ្ឋាន និងភស្តុតាងណាមួយដូចការលើកឡើងរបស់សាក្សីឡើយ ហើយសាក្សីនេះទៀតសោតក៏មិនមានអ្វីបញ្ជាក់ថា នៅថ្ងៃកើតហេតុបានស្ថិតនៅក្នុងកាស៊ីណូ និងបាននៅជាមួយឈ្មោះ [redacted]DONG នោះទេ លើសពីនេះទៅទៀតសាក្សីឈ្មោះ **ប៊ុន លីន** ក៏មិនបានបង្ហាញអំពីកាតសម្គាល់ខ្លួនដូចការអះអាងថា ខ្លួនជាបុគ្គលិកដែលធ្វើការងារនៅក្នុងកាស៊ីណូ អាត្លង់ទិច ហើយបានជួបភ្ញៀវឈ្មោះ [redacted] FAN CONG ឡើយ។ ជាងនេះទៅទៀតសាក្សីទាំងពីរក៏ថា ខ្លួនបានឃើញឈ្មោះ [redacted] FAN CONG ចូលលេងក្នុងកាស៊ីណូ ហើយពួកខ្លួនមិនបានអង្គុយជាមួយឈ្មោះ MENG FAN CONG ហៅ XIAO DONG ប៉ុន្តែតាមចម្លើយជនជាប់ចោទឈ្មោះ [redacted] FAN CONG បាននិយាយថា នៅពេលខ្លួនកំពុងលេងក្នុងកាស៊ីណូ គឺសាក្សីទាំង ០២នាក់នេះនៅក្បែរខ្លួន និងបានអះអាង បន្ថែមថា ឈ្មោះ **យ៉ុង** ជាតៃកុងឡាន និងឈ្មោះ **លីន** ជាអ្នកបកប្រែឱ្យខ្លួន។ ត្រង់ចំនុចនេះតុលាការយល់ឃើញថា ចម្លើយរបស់សាក្សី និងជនជាប់ចោទផ្ទុយគ្នា ហេតុនេះពុំអាចឱ្យក្រុមប្រឹក្សាជំនុំជម្រះជឿជាក់បានឡើយ។



Scanned with CamScanner

**៥.**តាមរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ចម្លើយរបស់ជនជាប់ចោទ សាក្សី និងភស្តុតាងនានាដែលមាននៅក្នុងសំណុំរឿងអាចបញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted]FAN CONG និងឈ្មោះ HUANG KUN ពិតជាបានរៀបចំគម្រោងទុកជាមុន និងធ្វើសកម្មភាពជិះរថយន្តដេញតាមរថយន្តជនរងគ្រោះ ក្នុងចេតនាសម្លាប់ហើយឈ្មោះ [redacted]FAN CONG ហៅ XIAO DONG បានយកកាំភ្លើងបាញ់ (គ្មានច្បាប់អនុញ្ញាត) ទៅលើជនរងគ្រោះឈ្មោះ PENG XU ភេទប្រុស បណ្តាលឱ្យស្លាប់ ដោយមានជនជាប់ចោទ ឈ្មោះ [redacted]XUAN YI និងឈ្មោះ [redacted] KAI JIN ក៏បានជួយសម្រួលដល់ការសម្រេចបទល្មើស តាមរយៈការជិះរថយន្តក្នុងចេតនាដេញកាក់រថយន្តជនរងគ្រោះ ដើម្បីឱ្យបក្សពួករបស់ខ្លួនសម្រេចនូវបទល្មើស។ ដែលសកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] FAN CONG ត្រូវបានច្បាប់កំណត់ថាជាបទល្មើស **ឃាតកម្មគិតទុកជាមុន និងកាន់កាប់អាវុធដោយគ្មានការអនុញ្ញាត**, ឈ្មោះ [redacted] KUN ត្រូវបានច្បាប់កំណត់ថាជាបទល្មើស **ឃាតកម្មគិតទុកជាមុន** ដោយឡែកសកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted]XUAN YI និងឈ្មោះ [redacted]KAI JIN ត្រូវបានច្បាប់កំណត់ថាជាបទល្មើស **សមគំនិតក្នុងអំពើឃាតកម្មគិតទុកជាមុន**។ ប៉ុន្តែជនជាប់ចោទឈ្មោះ [redacted]KUN ត្រូវបានចៅក្រមស៊ើបសួរបញ្ជូនមកជំនុំជម្រះតាមរយៈដីកាដំណោះស្រាយលេខ១៥៥ ដ.ដ.ស (ជ)/១២ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២២ ពីបទ **ឃាតកម្មគិតទុកជាមុន និងកាន់កាប់អាវុធដោយគ្មានការអនុញ្ញាត** ហេតុដូច្នេះគប្បីក្រុមប្រឹក្សាជំនុំជម្រះសម្រេចឱ្យជនជាប់ចោទឈ្មោះ [redacted]KUN រួចផុតបទចោទពីបទ **កាន់កាប់អាវុធដោយគ្មានការអនុញ្ញាត** តាមបញ្ញត្តិមាត្រា៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**៦.**អំពើរបស់ជនជាប់ចោទឈ្មោះ [redacted]KUN, ឈ្មោះ [redacted] XUAN YI, ឈ្មោះ [redacted]KAI JIN និងឈ្មោះ [redacted]FAN CONG ធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយសង្គម និងដកហូតអាយុជីវិតជនរងគ្រោះ ហើយជនជាប់ចោទមានស្មារតីយល់ដឹងគ្រប់គ្រាន់ចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត និងក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួន គប្បីតុលាការពិចារណាពីការផ្តន្ទាទោស តាមបញ្ញត្តិមាត្រា៣៨ នៃក្រមព្រហ្មទណ្ឌ។

**៧.**មានភស្តុតាង និងធាតុផ្សំគ្រប់គ្រាន់លើឈ្មោះ [redacted] KUN ភេទប្រុស ពីបទ **ឃាតកម្មគិតទុកជាមុន** បទល្មើសដែលបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា២០០ នៃក្រមព្រហ្មទណ្ឌ, ឈ្មោះ [redacted]FAN CONG ហៅ XIAO DONG ពីបទ **ឃាតកម្មគិតទុកជាមុន និងកាន់កាប់អាវុធដោយគ្មានការអនុញ្ញាត** បទល្មើសដែលបញ្ញត្តិផ្តន្ទាទោសតាមមាត្រា **២០០** និងមាត្រា **៤៩០** នៃក្រមព្រហ្មទណ្ឌ, ឈ្មោះ [redacted]XUAN YI និងឈ្មោះ [redacted]KAI JIN ពីបទ **សមគំនិតក្នុងអំពើឃាតកម្មគិតទុកជាមុន** បទល្មើសដែលបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា២៩ និងមាត្រា២០០ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅភូមិ១ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០២១។

**៨.**ពុំមានភស្តុតាង និងធាតុផ្សំគ្រប់គ្រាន់លើឈ្មោះ [redacted] KUN ពីបទ **កាន់កាប់អាវុធដោយគ្មានការអនុញ្ញាត** ប្រព្រឹត្តនៅភូមិ១ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ បទល្មើសដែលបញ្ញត្តិផ្តន្ទាទោសតាមមាត្រា៤៩០ នៃក្រមព្រហ្មទណ្ឌ។

**៩.**អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] KUN, ឈ្មោះ [redacted] FAN CONG, ឈ្មោះ [redacted]XUAN YI និងឈ្មោះ [redacted]KAI JIN ដកហូតជីវិតជនរងគ្រោះ ធ្វើឡើងតាមការបញ្ជា និងការរៀបចំគម្រោងរបស់ឈ្មោះ [redacted] LIAN QI, ឈ្មោះ [redacted]ZI និងឈ្មោះ [redacted]GE ពុំបានប្រើទារុណកម្ម និងអំពើឃោឃៅលើជនរងគ្រោះ។ គប្បីក្រុមប្រឹក្សាជំនុំជម្រះពិចារណាពីស្ថានសម្រាលទោសដល់ជនជាប់ចោទផ្អែកលើកាលៈទេសៈ និងសកម្មភាពរបស់ជនជាប់ចោទនីមួយៗតាមមាត្រា៩៣ និងមាត្រា៩៥ នៃក្រមព្រហ្មទណ្ឌ។

**១០.**ជនជាប់ចោទឈ្មោះ [redacted] KUN, ឈ្មោះ [redacted] XUAN YI, ឈ្មោះ [redacted]KAI JIN និងឈ្មោះ [redacted]FAN CONG បានប្រព្រឹត្តបទឧក្រិដ្ឋ ដែលនាំឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សន្តិសុខជាតិ។ គប្បីក្រុមប្រឹក្សាជំនុំជម្រះសម្រេចហាមឃាត់ការស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជាសម្រាប់រយៈពេល ០៥ (ប្រាំ)ឆ្នាំ បន្ទាប់ពីអនុវត្តទោសបឋមស្ថាពរតាមបញ្ញត្តិមាត្រា២០៦ នៃក្រមព្រហ្មទណ្ឌ។

**១១.**វត្ថុតាងរួមមាន ៖ ទូរស័ព្ទ ០៧គ្រឿង (ម៉ាក VIVO ពណ៌ខ្មៅ ចំនួន ០២គ្រឿង, IPHONE 6 ចំនួន ០១គ្រឿង, ម៉ាក VIVO ពណ៌ទឹកមាស ចំនួន ០១គ្រឿង, ម៉ាក REDMI ចំនួន ០១គ្រឿង និងម៉ាក អូប៉ូ ចំនួន ០១គ្រឿង) ជាសម្បត្តិ



Scanned with CamScanner

សម្រាប់ប្រព្រឹត្តបទល្មើស គប្បីតុលាការសម្រេចរឹបអូស តាមបញ្ញត្តិមាត្រា៦២ នៃក្រមព្រហ្មទណ្ឌ។ ដោយឡែកលិខិតឆ្លងដែន ចំនួន ០២ក្បាល (ឈ្មោះ [redacted] XUAN YI និងឈ្មោះ [redacted] KUN) ជាសម្ភារៈមិនជាប់ពាក់ព័ន្ធនឹងបទល្មើស គប្បីតុលាការសម្រេចប្រគល់ឱ្យម្ចាស់ដើមវិញ តាមបញ្ញត្តិមាត្រា៦២ នៃក្រមព្រហ្មទណ្ឌ។

១២.តាមកំណត់ហេតុបណ្តឹង ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២១ និងកំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] SHENG បញ្ជាក់ថា បងប្រុសរបស់ខ្លួនឈ្មោះ [redacted] XU ត្រូវគេបាញ់សម្លាប់។ ស្នើសុំទាមទារសំណងចំនួន ៥០០,០០០ (ប្រាំសែន)ដុល្លារអាមេរិក។ ប៉ុន្តែឈ្មោះ [redacted] SHENG ពុំមានភស្តុតាងឯកសារបញ្ជាក់ថា ខ្លួន និងជនរងគ្រោះពិតជាបងប្អូនបង្កើតនឹងគ្នាឡើយ។ ហេតុដូច្នេះឈ្មោះ [redacted] SHENG ពុំមានសិទ្ធិតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌឡើយ។ ក្រុមប្រឹក្សាជំនុំជម្រះនឹងមិនពិចារណាពីការទាមទារសំណងរដ្ឋប្បវេណីឈ្មោះ [redacted] SHENG ឡើយ។

## ហេតុដូច្នេះសម្រេច

១.ឱ្យឈ្មោះ [redacted] KUN ហៅ A ZHU ភេទប្រុស អាយុ ២២ឆ្នាំ ជនជាតិចិន (មានសាវតាជាតិដូចខាងលើ) **រួចផុតបទចោទ** ពីបទ **កាន់កាប់អាវុធដោយគ្មានការអនុញ្ញាត** ប្រព្រឹត្តនៅភូមិ១ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ បទល្មើសដែលបញ្ញត្តិផ្តន្ទាទោសតាមមាត្រា៤៩០ នៃក្រមព្រហ្មទណ្ឌ។

**២.ផ្តន្ទាទោសលើ**

២.១ ឈ្មោះ [redacted] KUN ហៅ A ZHU ភេទប្រុស អាយុ ២២ឆ្នាំ ជនជាតិចិន (មានសាវតាជាតិដូចខាងលើ) **ដាក់ពន្ធនាគារកំណត់រយៈពេល ១៨ (ដប់ប្រាំបី)ឆ្នាំ ពីបទ ឃាតកម្មគិតទុកជាមុន** ប្រព្រឹត្តនៅភូមិ១ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ បទល្មើសដែលបញ្ញត្តិផ្តន្ទាទោសតាមមាត្រា២០០ នៃក្រមព្រហ្មទណ្ឌ។

២.២ ឈ្មោះ [redacted] FAN CONG ហៅ XIAO DONG ភេទប្រុស អាយុ៣៤ឆ្នាំ ជនជាតិចិន (មានសាវតាជាតិដូចខាងលើ) **ដាក់ពន្ធនាគារកំណត់រយៈពេល ១៨ (ដប់ប្រាំបី)ឆ្នាំ** ពីបទ **ឃាតកម្មគិតទុកជាមុន និងកាន់កាប់អាវុធដោយគ្មានការអនុញ្ញាត** ប្រព្រឹត្តនៅភូមិ១ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ បទល្មើសដែលបញ្ញត្តិផ្តន្ទាទោសតាមមាត្រា២០០ និងមាត្រា ៤៩០ នៃក្រមព្រហ្មទណ្ឌ។

២.៣ ឈ្មោះ [redacted] XUAN YI ភេទប្រុស អាយុ២៤ឆ្នាំ ជនជាតិចិន (មានសាវតាជាតិដូចខាងលើ) **ដាក់ពន្ធនាគារកំណត់រយៈពេល ១៥ (ដប់ប្រាំ)ឆ្នាំ**

២.៤ ឈ្មោះ [redacted] KAI JIN ភេទប្រុស អាយុ ២៣ឆ្នាំ ជនជាតិចិន (មានសាវតាជាតិដូចខាងលើ) **ដាក់ដាក់ពន្ធនាគារកំណត់រយៈពេល ១៥ (ដប់ប្រាំ)ឆ្នាំ**

ពីបទ **សមគំនិតក្នុងអំពើឃាតកម្មគិតទុកជាមុន** ប្រព្រឹត្តនៅភូមិ១ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ បទល្មើសដែលបញ្ញត្តិផ្តន្ទាទោសតាមមាត្រា២៩ និងមាត្រា២០០ នៃក្រមព្រហ្មទណ្ឌ។

៣.ហាមឃាត់ដល់ឈ្មោះ [redacted] KUN ហៅ A ZHU ភេទប្រុស អាយុ ២២ឆ្នាំ ជនជាតិចិន (មានសាវតាជាតិដូចខាងលើ), ឈ្មោះ [redacted] FAN CONG ហៅ XIAO DONG ភេទប្រុស អាយុ៣៤ឆ្នាំ ជនជាតិចិន (មានសាវតាជាតិដូចខាងលើ), ឈ្មោះ [redacted] XUAN YI ភេទប្រុស អាយុ២៤ឆ្នាំ ជនជាតិចិន (មានសាវតាជាតិដូចខាងលើ) និងឈ្មោះ [redacted] KAI JIN ភេទប្រុស អាយុ ២៣ឆ្នាំ ជនជាតិចិន (មានសាវតាជាតិដូចខាងលើ) ស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជារយៈពេល ០៥ (ប្រាំ)ឆ្នាំ បន្ទាប់ពីអនុវត្តទោសក្នុងពន្ធនាគាររួចរាល់ តាមបញ្ញត្តិមាត្រា២០៦ នៃក្រមព្រហ្មទណ្ឌ។

**៤.រឹបអូសវត្ថុតាងរួមមាន ៖** ទូរស័ព្ទ ០៧គ្រឿង (ម៉ាក VIVO ពណ៌ខ្មៅ ចំនួន ០២គ្រឿង, IPHONE 6 ចំនួន ០២គ្រឿង, ម៉ាក VIVO ពណ៌ទឹកមាស ចំនួន ០១គ្រឿង, ម៉ាក REDMI ចំនួន ០១គ្រឿង និងម៉ាក អ៊ីប្ប ចំនួន ០១គ្រឿង) តាមបញ្ញត្តិមាត្រា៦២ នៃក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

**៥.ប្រគល់ឱ្យម្ចាស់ដើមវិញនូវ ៖** លិខិតឆ្លងដែនចំនួន ០២ក្បាល (ឈ្មោះ[redacted]XUAN YI និងឈ្មោះ HUANG KUN) តាមបញ្ញត្តិមាត្រា៦២ នៃក្រមព្រហ្មទណ្ឌ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃពុធ ១០កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦ ត្រូវនឹងថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈនៅថ្ងៃព្រហស្បតិ៍ ១០កើត ខែកត្ដិក ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦ ត្រូវនឹងថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ[redacted]KUN, ឈ្មោះ [redacted]XUAN YI, ឈ្មោះ[redacted]KAI JIN និងឈ្មោះ[redacted]FAN CONG។

ទុកសិទ្ធិឱ្យប្ដឹងឧទ្ធរណ៍នៅក្នុងកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| --- | --- | --- | --- |
| [redacted] | [redacted] | [redacted] | [redacted] |



Scanned with CamScanner